# ហេតុផលទាំង១០យ៉ាង ដែលត្រូវជឿថា ព្រះពិតជាមានមែន

## ១. មនុស្សមិនអាចជៀសផុតពីសេចក្តីជំនឿ

មនុស្សម្នាក់ៗសុទ្ធតែមានជំនឿលើអ្វីមួយ។ គ្មាននរណាម្នាក់អាចអត់ទ្រាំនឹងភាពតប់ប្រមល់ និងទុក្ខលំបាក់ក្នុងជីវិត ដោយគ្មានជំនឿទៅលើអ្វីមួយនោះឡើយ ទោះគេមិនអាចបកស្រាយពន្យល់អំពីការនោះក៏ដោយ។ មានមនុស្សជាច្រើនដែលមិនជឿថាព្រះមានមែន តែពួកគេមិនអាចបញ្ជាក់ថា ព្រះ*ពិតជាមិនមាន* ឡើយ។ យ៉ាងណាមិញ ពួកអ្នកដែលជឿលើព្រះថាព្រះមានច្រើនអង្គ ក៏មិនអាចបញ្ជាក់ថា *អ្វីៗគ្រប់យ៉ាង* ជាព្រះឡើយ។ ពួកអ្នកដែលមានជំនឿនិយមលើតែការអ្វីដែលជាក់ស្តែង មិនអាចបញ្ជាក់ថា ការអ្វីដែលសំខាន់ចំពោះពួកគេ ក្នុងពេលអនាគត គឺជាការអ្វីដែល *មានប្រយោជន៍* ចំពោះពួកគេក្នុងពេលបច្ចុប្បន្នឡើយ។ មានមនុស្សមួយក្រុមទៀតជឿថា គ្មានភស្តុតាងបញ្ជាក់ថា ព្រះមានពិតឬអត់ឡើយ តែពួកគេក៏មិនអាចបញ្ជាក់ថា មនុស្ស *អាចដឹងថា* ព្រះមានមែន ឬក៏អត់ឡើយ។ ដូចនេះ និយាយរួម មនុស្សមិនអាចជៀសផុតពីសេចក្តីជំនឿបានឡើយ ទោះបីជាយើងបានសម្រេចចិត្តថា យើងជឿតែខ្លួនឯងក៏ដោយ។ យើងច្រើនតែសម្រេចចិត្តជឿលើអ្វីមួយ ដោយសំអាងទៅលើហេតុផល ឬភស្តុតាងដែលយើងគិតថាសមរម្យ ឬអាចទទួលយកបាន។ តើយើងអាចបកស្រាយអំពីភស្តុតាងនោះយ៉ាងដូចម្តេចខ្លះ ហើយតើយើង*ព្រម* ជឿលើនរណា ឬជឿលើអ្វី?(លូកា ១៦:១៦)

## ២. ដែនកំណត់នៃវិទ្យាសាស្ត្រ

វិធីសាស្ត្រស្រាវជ្រាវរបស់វិទ្យាសាស្ត្រ មានដែនកំណត់ ដោយសារគេអាចធ្វើការសន្និដ្ឋាន ដោយផ្អែកទៅលើការអ្វីដែលគេអាចវាស់ស្ទង់ និងអាចធ្វើឡើងវិញប្រាំដែលតែប៉ុណ្ណោះ។ បានសេចក្តីថា វិធីសាស្ត្រស្រាវជ្រាវរបស់វិទ្យាសាស្ត្រមិនអាចបកស្រាយ អំពីបញ្ហានៃដើមកំណើតដំបូងបំផុតរបស់សព្វសារពើ ឬអំពីអត្ថន័យ ឬសីលធម៌បានឡើយ។ ដើម្បីបកស្រាយអំពីបញ្ហាទាំងនេះ វិទ្យាសាស្ត្រពឹងផ្អែកទៅលើគោលតម្លៃ និងជំនឿផ្ទាល់ខ្លួនរបស់បុគ្គលដែលប្រើវិទ្យាសាស្ត្រនោះ។ ដូចនេះ វិទ្យាសាស្ត្រមានសក្តានុពលដ៏សម្បើម សម្រាប់សេចក្តីល្អ ក៏ដូចជាសេចក្តីអាក្រក់។ គេអាចប្រើវិទ្យាសាស្ត្រដើម្បីបង្កើតថ្នាំវ៉ាក់សាំង ឬបង្កើតថ្នាំពល់ និងបង្កើតរោងចក្រអគ្គីសនីនុយក្លេអ៊ែ ឬបង្កើតអាវុធនុយក្លេអ៊ែ។ គេអាចប្រើវា ដើម្បីសម្អាតក៏ដូចជាបំពល់បរិស្ថាន។ គេអាចប្រើវិទ្យាសាស្ត្រដើម្បីជជែករកខុសត្រូវថ្វាយព្រះ ក៏ដូចជាដើម្បីប្រឆាំងនឹងព្រះអង្គផងដែរ។ វិទ្យាសាស្ត្រមិនបានផ្តល់ឲ្យមនុស្ស នូវការបង្រៀនផ្នែកសីលធម៌ ឬគោលតម្លៃសម្រាប់ឲ្យមនុស្សរស់នៅតាមឡើយ។ វិទ្យាសាស្ត្រគ្រាន់តែអាចបង្ហាញយើង ពីរបៀបដែលច្បាប់ធម្មជាតិមានដំណើរការ តែមិនអាចប្រាប់យើងពីប្រភពដើមនៃច្បាស់ធម្មជាតិបានឡើយ។

## ៣. បញ្ហារបស់ទ្រឹស្តីអំពីការវិវត្តន៍

អ្នកខ្លះបានសន្និដ្ឋានថា អ្នកវិទ្យាសាស្ត្របានពន្យល់ច្បាស់លាស់ អំពីការវិវត្តន៍នៃជីវិតលើផែនដី ដោយមានភស្តុតាហើយ ដូចនេះ ជំនឿលើព្រះមិនមានភាពចាំបាច់ទេ។ ទោះជាយ៉ាងណាក៏ដោយ ការសន្និដ្ឋាននេះបានមើលរំលងបញ្ហាមួយចំនួន។ ទ្រឹស្តីអំពីការវិវត្តន៍បានអះអាងថា មនុស្សបានវិវត្តន៍ពីសត្វស្វា ហើយសត្វស្វាបានវិវត្តន៍តគ្នា ពីសត្វប្រភេទផ្សេងទៀតជាច្រើនតំណ តែអ្នកវិទ្យាសាស្ត្រ ក៏បានបញ្ជាក់ផងដែរថា មានតំណរខ្លះបានបាត់ ក្នុងដំណើរនៃការវិវត្តន៍ដ៏យូរអង្វែងនោះ ហើយគេមិនទាន់រកតំណដែលបាត់នោះឃើញទេ។ ទោះបីជាគេសន្និដ្ឋានថា ថ្ងៃណាមួយ អ្នកវិទ្យាសាស្ត្រនឹងរកឃើញ "តំណដែលបាត់" ក្នុងចំនួនល្មមដែលអាចបញ្ជាក់ថា ជីវិតបានកើតមាន ហើយអភិវឌ្ឍឃើតៗ ក្នុងរយៈពេលដ៏វែងយ៉ាងណាក៏ដោយ ក៏ច្បាប់នៃប្រូបាប ឬច្បាប់នៃភាពដែលអាចកើតមាន នៅតែបង្ហាញពីការដែលរបស់ទាំងអស់ត្រូវការព្រះអាទិករបង្កើតពួកវាមក។ ហេតុនេះហើយ បានជាមានអ្នកវិទ្យាសាស្ត្រជាច្រើន ដែលជឿលើទ្រឹស្តីនៃការវិវត្តន៍ ក៏បានជឿផងដែរថា ចក្រវាលដ៏ធំល្វឹងល្វើយ និងមានភាពចម្រុះដ៏ស្មុគស្មាញ មិនមែន "ស្រាប់តែកើតមក ដោយឯកឯងឡើយ"។ មានមនុស្សជាច្រើនបានគិតថា ខ្លួនត្រូវតែទទួលស្គាល់ភាពដែលអាចមាន ឬភាពទំនងជាមានអ្នករចនាដែលមានបញ្ញាម្នាក់ ដែលបានផ្តល់ឲ្យនូវគ្រឿងផ្សំនៃជីវិតទាំងអស់ ហើយក៏បានដាក់ច្បាប់ធម្មជាតិ ឲ្យគ្រប់គ្រងការអភិវឌ្ឍន៍នៃជីវិតទាំងអស់។

## ៤. ទំលាប់នៃចិត្តរបស់មនុស្ស

គេបានពិពណ៌នាថា មនុស្សជាតិ ជាជីវិតដែលមានជំនឿសាសនា ដែលមិនអាចលប់បំបាត់បានឡើយ។ ពេលដែលមនុស្សជាទូទៅជួបបញ្ហាដ៏តក់ស្លត់ ដោយមិនបានត្រៀមខ្លួនទុកជាមុន ពួកគេច្រើនតែភ្លាត់មាត់អធិស្ឋាន បួងសួង ឬភ្លាត់មាត់និយាយចេញឈ្មោះព្រះណាមួយ ជារបៀបភ្ញាក់ផ្អើល។ អ្នកដែលគិតថា ការភ្លាត់មាត់នេះជាទម្លាប់អាក្រក់ ឬខុសសីលធម៌សង្គម គឺបានត្រឹមតែចោទសួរ ជាសំណួរដែលគេមិនអាចឆ្លើយបាន។ ទោះគេខំបដិសេធថា ព្រះមិនមានយ៉ាងណាក៏ដោយ ក៏គេនៅតែមិនអាចបដិសេធអាថ៌កំបាំងនៃជីវិតបានឡើយ។ ទោះគេព្យាយាមលប់បំបាត់ការនិយាយអំពីព្រះ នៅក្នុងភាសានៃការរស់នៅ ជាជនស៊ីវិលក៏ដោយ ក៏គេមិនអាចធ្វើឲ្យមនុស្សលែងចង់ដឹងចង់យល់ អំពីអ្វីដែលនឹងកើតមាន បន្ទាប់ពីជីវិតនៅផែនដីនេះអស់ទៅឡើយ(សាស្តា ៣:១១)។ ចិត្តរបស់យើងស្រេកឃ្លានចង់បាន និងចង់យល់អំពីការអ្វីដែលទាក់ទងនឹងសេចក្តីពិត សម្រស់ និងសេចក្តីស្រឡាញ់។ សូម្បីតែនៅពេលដែលមនុស្សយើងខឹងនឹងព្រះ ដែលបានអនុញ្ញាតឲ្យមានភាពអយុត្តិធម៌ និងទុក្ខវេទនា កើតមានក្នុងលោកិយនេះ ក៏សម្បជញ្ញៈ ឬបញ្ញាចិត្តរបស់យើង បាននាំឲ្យយើងគិតវែកញែកការខុសត្រូវ ហើយប្រកែកថា ជីវិតរបស់មនុស្សយើងរស់នៅមិនបានល្អ តាមដែលគួររស់នៅឡើយ(រ៉ូម ២:១៤-១៥)។ ម្យ៉ាងទៀត យើងច្រើនតែងាកទៅរកការអ្វីដែលធំជាងយើងដោយមិនដឹងខ្លួន ជាជាងងាកទៅរកការអ្វីដែលតូចជាងយើង។

## ៥. ប្រវត្តិរបស់កណ្ឌលោកុប្បត្តិ

ពេលយើងចាប់ផ្តើមអានព្រះគម្ពីរ ពីទំព័រដំបូង យើងឃើញថា ពាក្យខាងដើមនៃព្រះគម្ពីរ ក្នុងកណ្ឌលោកុប្បត្តិបានសន្និដ្ឋានថា ព្រះពិតជាមានមែន។ ទោះជាយ៉ាងណាក៏ដោយ កណ្ឌលោកុប្បត្តិត្រូវបាននិពន្ធឡើង ដោយលោកម៉ូសេ ក្នុងសម័យកាលមួយក្នុងប្រវត្តិសាស្ត្រ។ លោកម៉ូសេបានសរសេរពាក្យខាងដើមនោះថា "កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី"។ គាត់បានចាប់ផ្តើមនិពន្ធកណ្ឌលោកុប្បត្តិបន្ទាប់ពីប្រជាជនអ៊ីស្រាអែលបានភាសខ្លួនចេញពីនគរអេស៊ីព្ទ និងបន្ទាប់ពីមានហេតុការណ៍នៃការអស្ចារ្យជាច្រើនបានកើតឡើង ដែលមានជនជាតិអ៊ីស្រាអែល និងជនជាតិអេស៊ីព្ទរាប់លាននាក់បានឃើញផ្ទាល់ភ្នែក។ ចាប់តាំងពីសម័យដែលជនជាតិអ៊ីស្រាអែលភាសខ្លួនពីនគរអេស៊ីព្ទ រហូតមកដល់សម័យដែលព្រះមែស៊ីយាងមកចាប់កំណើត ព្រះនៃព្រះគម្ពីរបានប្រើព្រឹត្តិការណ៍ដ៏អស្ចារ្យជាច្រើន ដើម្បីបង្ហាញថា ព្រះអង្គពិតជាព្រះដែលមានពិតមែន ដោយព្រឹត្តិការណ៍ទាំងនោះ បានកើតឡើងដោយមានការកត់ត្រាអំពីកាលបរិច្ឆេទ និងទីកន្លែងដែលមានពិតៗ។ ដូចនេះ អ្នកណាដែលមិនជឿការអះអាងនេះ អាចទៅមើលទីកន្លែងពិតៗ និងទៅជួបមនុស្សនៅទីនោះ ដើម្បីពិនិត្យមើលភស្តុតាងដោយខ្លួនឯងបាន។

## ៦. ប្រជាជាតិអ៊ីស្រាអែល

ជាញឹកញាប់ គេច្រើនតែនិយាយអំពីជនជាតិអ៊ីស្រាអែល ដើម្បីប្រកែកគ្នាប្រឆាំងនឹងព្រះ។ មានមនុស្សជាច្រើនបានយល់ថា ពួកគេពិបាកនឹងជឿលើព្រះមួយអង្គ ដែលលំអៀងទៅរក "រាស្ត្រជ្រើសតាំង" របស់ព្រះអង្គ។ អ្នកខ្លះទៀតកាន់តែពិបាកជឿលើព្រះអង្គ ពេលដែលព្រះអង្គមិនបានការពារ "រាស្ត្រជ្រើសតាំង"របស់ព្រះអង្គ ឲ្យរួចពីអំពើប្រល័យពូជសាសន៍ ក្នុងសម័យសង្គ្រាមលោកលើកទីពីរ ដែលមានពួកគេជាង៦លាននាក់ត្រូវពួកណាហ្ស៊ីអ៊ីត្លែ ដឹកក្នុងទូរថភ្លើងយកទៅសម្លាប់ក្នុងបន្ទប់ហ្គាស និងក្នុងឡសម្រាប់ដុតសម្លាប់ ក្នុងមន្ទីរប្រមូលផ្តុំអូសវីត និងដាឆូជាដើម។ ប៉ុន្តែ ព្រះបានកត់ទុកអំពីអនាគតរបស់ប្រជាជាតិអ៊ីស្រាអែលរួចជាស្រេចហើយ គឺចាប់តាំងពីដើមដំបូងនៃប្រវត្តិសាស្ត្រនៃគ្រាសញ្ញាចាស់មកម្ល៉េះ។ លោកម៉ូសេ និងហោរាដទៃទៀត មិនគ្រាន់តែបានថ្លែងទំនាយថា ពួកអ៊ីស្រាអែលនឹងបានចូលកាន់កាប់ទឹកដីសន្យាប៉ុណ្ណោះទេ តែថែមទាំងទទួលរងនូវទុក្ខវេទនាលើសពីពេលមុនទៀត ព្រមទាំងត្រូវរស់នៅបែកខ្ញែករប៉ាត់រប៉ាយ នៅទូទាំងពិភពលោក ក្រោយមក ពួកគេនឹងប្រែចិត្តងាកមករកព្រះវិញ ហើយនៅទីបំផុត ព្រះអង្គនឹងស្អាងពួកគេឡើងវិញ នៅគ្រាចុងក្រោយ(ចោទិយកថា ២៨-៣៤ អេសាយ ២:១-៥ អេសេគាល ៣៧-៣៨)។

## ៧. ការអះអាងរបស់ព្រះគ្រីស្ទ

មនុស្សជាច្រើន ដែលមិនជឿថាព្រះមានពិតមែន បានគិតថា "បើសិនជាព្រះសព្វព្រះទ័យឲ្យពួកគេជឿលើព្រះអង្គ នោះព្រះអង្គមុខជាបង្ហាញព្រះអង្គទ្រង់ឲ្យពួកគេបានឃើញជាក់ជាមិនខានទេ"។ តាមពិតព្រះបានបង្ហាញព្រះអង្គទ្រង់ ឲ្យមនុស្សឃើញរួចហើយ នោះបើយោងតាមព្រះគម្ពីរបរិសុទ្ធ។ ក្នុងសតវត្សរ៍ទី៧ មុនគ្រីស្ទសករាជ ហោរាអេសាយ បានមានប្រសាសន៍ថា ព្រះនឹងប្រទាននូវទីសំគាល់មួយ ឲ្យរាស្ត្រព្រះអង្គបានឃើញ។ ស្ត្រីព្រហ្មចារីយ៍ម្នាក់ នឹងបង្កើតបានបុត្រាមួយអង្គ ដែលព្រះនាមព្រះអង្គមានន័យថា "ព្រះគង់ជាមួយយើង"(អេសាយ ៧:១៤ ម៉ាថាយ ១:២៣)។ លោកអេសាយបានមានប្រសាសន៍ទៀតថា គេនឹងហៅព្រះរាជបុត្រាមួយអង្គនេះថា "ព្រះដ៏ជួយគំនិតយ៉ាងអស្ចារ្យ ព្រះដ៏មានព្រះចេស្តា ព្រះវបិតាដ៏គង់នៅអស់កល្ប និងជាម្ចាស់នៃមេត្រីភាព"(អេសាយ ៩:៦)។ លោកហោរាក៏មានប្រសាសន៍ផងដែរថា ព្រះរាជបុត្រានឹងសុគត ដើម្បីលោះរាស្ត្ររបស់ព្រះអង្គឲ្យរួចពីបាប ក្រោយមកព្រះអង្គក៏មានព្រះជន្មឡើងវិញ ហើយព្រះក៏បានដំកើងព្រះនាមព្រះអង្គឡើង(អេសាយ ៥៣)។ ព្រះគម្ពីរសញ្ញាថ្មីបានចែងថា ព្រះយេស៊ូវបានអះអាងថា ព្រះអង្គជាព្រះមែស៊ី។ លោកប៉ុនទាស-ពីឡាត់ ដែលជាអភិបាលស្រុកយូដា នៅសម័យនោះ បានធ្វើជាអធិបតី ក្នុងការ

ជំនុំជម្រះទោស ដោយឆ្កាងសម្លាប់ ពីបទដែលព្រះអង្គបានតាំងខ្លួនជាស្តេចនៃសាសន៍អ៊ីស្រាអែល និងដោយសារព្រះអង្គបានតាំងខ្លួនឲ្យស្មើនឹងព្រះ(យ៉ូហាន ៥:១៨)។

## ៨. ភស្តុតាងនៃការអស្ចារ្យ

ពួកសិស្សដំបូងរបស់ព្រះយេស៊ូវ សុទ្ធតែបានអះអាងដូចគ្នាថា ព្រះអង្គមិនគ្រាន់តែបានប្រកាសថា ព្រះអង្គជាព្រះមែស៊ីដែលគេបានទន្ទឹងរង់ចាំជាយូរមកហើយប៉ុណ្ណោះឡើយ គឺព្រះអង្គថែមទាំងបានធ្វើការអស្ចារ្យច្រើន ឲ្យមនុស្សនៅសម័យនោះបានឃើញផ្ទាល់ភ្នែក។ សាក្សីទាំងអស់នេះ បាននិយាយថា ពួកគេបានជឿព្រះអង្គ ពេលបានឃើញព្រះអង្គប្រោសជនពិការឲ្យជា និងដើរលើទឹក ហើយបន្ទាប់មក ក៏បានសុគតព្រះទ័យសុគត យ៉ាងវេទនាបំផុត ដោយគ្មានកំហុសអ្វីសោះ ហើយក្រោយមកព្រះអង្គក៏បានមានព្រះជន្មរស់ឡើងវិញ(១កូរិនថូស ១៥:១-៨)។ អ្វីដែលគួរឲ្យជឿបំផុតនោះ គឺការដែលពួកគេអះអាងថា មានមនុស្សជាច្រើនបានឃើញ និងជជែកជាមួយព្រះអង្គ បន្ទាប់ពីគេឃើញផ្នូរព្រះអង្គនៅទទេ និងមុនពេលដែលពួកគេបានឃើញព្រះអង្គហោះឡើងទៅលើពពក។ សាក្សីទាំងអស់នេះ នឹងបានទទួលផលចំណេញពីលោកិយ នៅក្នុងការអះអាងរបស់ខ្លួនឡើយ ផ្ទុយទៅវិញ មានពួកគេជាច្រើនត្រូវគេបៀតបៀនសម្លាប់ ដោយសារជំនឿ និងបានអះអាងឥតឈប់ឈរថា ព្រះមែស៊ីដែលសាសន៍អ៊ីស្រាអែលបានរង់ចាំ ជាយូរមកហើយ បានរស់នៅក្នុងចំណោមពួកគេ ព្រះអង្គបានលះបង់ព្រះជន្ម ដើម្បីលោះបាបមនុស្សរាល់គ្នា ហើយព្រះអង្គបានមានព្រះជន្មឡើងវិញ ដើម្បីបញ្ជាក់ដល់ពួកគេថា ព្រះអង្គពិតជាមានអំណាចនាំពួកគេទៅឯព្រះវរបិតាមែន។ ដូចនេះបើសិនជា ព្រះអង្គមិនបានមានព្រះជន្មឡើងវិញទេ នោះពួកគេក៏មិនហ៊ានលះបង់ជីវិត ដើម្បីចេញទៅប្រកាស ឲ្យគេជឿព្រះអង្គឡើយ។

## ៩. ភាពល្អិតនៃធម្មជាតិ

អ្នកដែលមិនជឿថា ព្រះពិតជាមានមែន មិនបានគិតឲ្យស៊ីជម្រៅអំពីវត្តមានរបស់ព្រះអង្គទេ។ ពួកគេលើកហេតុផលថា បើសិនជាព្រះមានភាពអស្ចារ្យល្មមនឹងបង្កើតចក្រវាលបានមែន នោះព្រះអង្គមានភាពធំធេងពេក គឺមិនអាចខ្វល់អំពីយើងទេ។ ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវបានបញ្ជាក់ថា ព្រះពិតជាបានយកព្រះទ័យទុកដាក់ចំពោះយើងមែន ព្រោះព្រះអង្គបានរចនា និងបង្កើតពិភពធម្មជាតិ ដោយការល្អិតបំផុត និងផ្ចិតផ្ចង់ផង។ ព្រះអង្គបានមានបន្ទូល អំពីព្រះដែលមិនគ្រាន់តែបានជ្រាបអំពីចលនានីមួយៗដែលរូបកាយរបស់យើងមានប៉ុណ្ណោះទេ តែថែមទាំងជ្រាបអំពីបំណងចិត្ត និងគំនិតដែលមានក្នុងចិត្តយើងទៀតផង។ ព្រះយេស៊ូវបានបង្រៀនថា ព្រះជ្រាបថា សក់នៅលើក្បាលយើងមានប៉ុន្មានសរសៃ និងជ្រាបថា ចិត្តយើងកំពុងខ្វល់ពីអ្វី ហើយសូម្បីតែសត្វចាបមួយក្បាលដែលធ្លាក់ ក៏ព្រះអង្គជ្រាបដែរ(ទំនុកដំកើង ១៣៩ ម៉ាថាយ ៦)។

## ១០. បទពិសោធន៍របស់បុគ្គលអាចឆ្លើយប្រាប់បាន

ព្រះគម្ពីរបានចែងថា ព្រះបានរៀបចំកាលៈទេសៈនៃជីវិត តាមរបៀបដែលជម្រុញឲ្យយើង ស្វែងរកព្រះអង្គ(កិច្ចការ ១៧:២៦)។ ព្រះគម្ពីរបានចែងថា ព្រះអង្គតែងគង់នៅជិតបង្កើត គឺជិតល្មមនឹងឲ្យគេរកព្រះអង្គឃើញ ទោះគេបានស្វែងរកព្រះអង្គ ឬអត់ក៏ដោយ(ខ.២៧)។ យោងតាមសេចក្តីបង្រៀនរបស់សាវ័កប៉ុល ព្រះជាវិញ្ញាណ ដែលដោយសារទ្រង់ នោះ "យើងរាល់គ្នាបានរស់ កំរើក ហើយមាននៅផង"(ខ.២៨)។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបានបញ្ជាក់ច្បាស់ថា យើងត្រូវឈោងទៅរកព្រះតាមការណែនាំរបស់ព្រះអង្គ គឺមិនមែនតាមមធ្យោបាយរបស់យើងទេ។ ព្រះអង្គបានសន្យាថា យើងនឹងរកព្រះអង្គឃើញ ជាពិសេស នៅពេលដែលយើងទទួលស្គាល់ថា យើងត្រូវការព្រះអង្គ ហើយព្រមទុកចិត្តព្រះអង្គ ជាជាងទុកចិត្តខ្លួនឯង។

បើសិនជាអ្នកបានបើកចំហរចិត្ត ព្រមទទួលជឿថា ព្រះពិតជាមានមែន តែអ្នកមិនដឹងច្បាស់ថា អ្នកអាចទទួលស្គាល់ថា ព្រះយេស៊ូវជា "ព្រះដែលបានយាងមកយកកំណើតជាមនុស្ស"ឬក៏អត់ នោះមិនមែនមានតែអ្នកទេដែលមានបញ្ហានេះ។ ព្រះយេស៊ូវជាគ្រូបង្រៀនព្រះបន្ទូលមកពីស្រុកណាសារ៉ែត ដែលបានសន្យាថា នឹងជួយដល់អស់អ្នកដែលយកចិត្តទុកដាក់ អំពីការធ្វើតាមបំណងព្រះហឫទ័យព្រះ។ ព្រះអង្គបានមានបន្ទូលថា "បើអ្នកណាចង់ធ្វើតាមព្រះហឫទ័យទ្រង់ នោះនឹងបានដឹងជាសេចក្តីបង្រៀននេះមកពីព្រះ ឬជាខ្ញុំនិយាយដោយអាងខ្លួនខ្ញុំ"(យ៉ូហាន ៧:១៧)។

បើអ្នកបានទទួលស្គាល់ភស្តុតាង ដែលព្រះបានបើកសម្តែងព្រះអង្គទ្រង់ តាមរយៈព្រះរាជបុត្រាព្រះអង្គហើយ នោះសូមចាំថា ព្រះគម្ពីរបានចែងថា ព្រះគ្រីស្ទបានសុគតដើម្បីលោះយើងឲ្យរួចពីបាប ហើយអស់អ្នក ដែលជឿព្រះអង្គ នឹងបានទទួលការអត់ទោសបាប និងជីវិតអស់កល្បជានិច្ច ជាអំណោយ ដោយឥតគិតថ្លៃ។ សេចក្តីសង្គ្រោះដែលព្រះគ្រីស្ទប្រទាន មិនមែនជារង្វាន់ សម្រាប់ការខិតខំធ្វើការល្អនោះទេ តែជាអំណោយដល់អស់អ្នក ដែលបានទទួលជឿព្រះអង្គ ទោះបានឃើញភស្តុតាងឬអត់ក៏ដោយ(យ៉ូហាន ៥:២៤ រ៉ូម ៤:៥ អេភេសូរ ២:៨-១០)។

ដើម្បីទទួលសេចក្តីសង្គ្រោះ ដែលជាអំណោយរបស់ព្រះ អ្នកអាចអធិស្ឋានតាមលំនាំដូចតទៅនេះថា "ព្រះអម្ចាស់យេស៊ូវអើយ ទូលបង្គំដឹងថា ទូលបង្គំជាមនុស្សមានបាប។ ទូលបង្គំមិនអាចជួយសង្គ្រោះខ្លួនឯងបានឡើយ។ ទទួលបង្គំជឿថា ព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង ដើម្បីលោះបាបទូលបង្គំ។ ទូលបង្គំជឿថា ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ ហើយព្រះអង្គសព្វព្រះទ័យនឹងយាងចូលគង់ ក្នុងជីវិតរបស់អស់អ្នក ដែលជឿព្រះអង្គ។ ទូលបង្គំសូមទទួលព្រះអង្គជាព្រះអង្គសង្គ្រោះ។ ទូលបង្គំសូមទទួលការអស់ទោសបាប និងជីវិតអស់កល្បជានិច្ច។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ។ ទូលបង្គំសូមអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាមែន"។

បើអ្នកបានសម្រេចចិត្តទទួលជឿព្រះគ្រីស្ទហើយ សូមអញ្ជើញទៅរកព្រះវិហារដែលនៅក្បែរផ្ទះរបស់អ្នក។ សូមអ្នកអធិស្ឋាន សូមឲ្យព្រះអម្ចាស់ដឹកនាំអ្នក ទៅរកព្រះវិហារ ដែលនឹងបង្រៀនព្រះគម្ពីរយ៉ាងត្រឹមត្រូវ ដោយវិញ្ញាណនៃសេចក្តីស្រឡាញ់ ដូចព្រះគ្រីស្ទ។ អ្នកអាចសរសេរអ៊ីមែល ផ្ញើមកយើងខ្ញុំ តាមអស័យដ្ឋាន rbc@odg.org ហើយអ្នកទទួលសៀវភៅ សម្រាប់សិក្សាព្រះបន្ទូលប្រចាំថ្ងៃ ដោយឥតគិតថ្លៃ ដែលយើងខ្ញុំបានរៀបចំ ដើម្បីជួយឲ្យអ្នកលូតលាស់ ក្នុងជីវិតថ្មី ជាកូនរបស់ព្រះ។

រក្សាសិទ្ធិគ្រប់យ៉ាងដោយ: © 2015 ODB Ministries ( website: www.odb.org )
ចេញផ្សាយដោយ : ODB Cambodia ( email: cambodia@rbc.org, Tell: 087 233 907,
website: http://khmer-odb.org, FB page : https://www.facebook.com/RBCCambodia )

នំម៉ាណាប្រចាំថ្ងៃ

